**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**កំពង់ផែស្វយ័តក្រុងព្រះសីហនុ**

លេខ: ០៧៨ សជណ/កសស/អជក

ថ្ងៃអង្គារ ១២រោច ខែអាសាឍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ខេត្តព្រះសីហនុ ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២៥

# សេចក្តីជូនដំណឹង

## ស្តីពី

## ការចូលរួមដោះស្រាយ ដើម្បីបង្កើនប្រសិទ្ធភាព និងទប់ស្កាត់ការស្ទះចរាចរណ៍នាវា-រថយន្ត នៅកំពង់ផែស្វយ័តក្រុងព្រះសីហនុ (កសស)

**យោង** ៖ - ស្មារតីអង្គប្រជុំក្រុមប្រឹក្សាភិបាល កសស អាណត្តិទី៩ លើកទី៤ ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៥
- លិខិតលេខ ៦៧០៩ សហវ.លស ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៥ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងចំណារដ៏ខ្ពង់ខ្ពស់របស់ **សម្តេចធិបតី នាយករដ្ឋមន្ត្រី** ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០២៥
- ស្មារតីកិច្ចប្រជុំពិគ្រោះយោបល់រវាង កសស, សមត្ថកិច្ចគយ, នគរបាលច្រកទ្វារ, ក្រុមហ៊ុននាវា, ក្រុមហ៊ុនដឹកជញ្ជូន, ភ្នាក់ងារជើងសារគយ និងភ្នាក់ងារជើងសារកំពង់ផែ ។

កំពង់ផែស្វយ័តក្រុងព្រះសីហនុ (កសស) សូមថ្លែងអំណរគុណជូនចំពោះ ក្រុមហ៊ុននាវា ក្រុមហ៊ុនដឹកជញ្ជូនដោយរថយន្ត អតិថិជន និងអ្នកប្រើប្រាស់ផែ ដែលបាននិងកំពុងបន្តគាំទ្រប្រើប្រាស់ កសស ជាច្រកទ្វារចរាចរទំនិញចូល-ចេញព្រះរាជាណាចក្រកម្ពុជា និងពិភពលោក ។ នៅក្នុងឆ្នាំ២០២៤ កសស សម្រេចបានបរិមាណកុងតឺន័រឆ្លងកាត់លើសពី ១លានTEUs កើនឡើងជាង ២៩% ជាមួយគ្នានេះ យោងតាមលទ្ធផលអាជីវកម្ម-សេវាកម្ម រយៈពេល៦ខែ ដើមឆ្នាំ២០២៥ សង្កេតឃើញថា បរិមាណកុងតឺន័រឆ្លងកាត់ កសស មានកំណើនគួរអោយកត់សម្គាល់ (២៥%) ប្រៀបធៀបទៅនឹងរយៈពេលដូចគ្នា ឆ្នាំ២០២៤ ។

យោងទៅតាមសមត្ថភាពរបស់ កសស ដូចជា ៖ សមត្ថភាពផែ (បរិមាណកុងតឺន័រឆ្លងកាត់ ១លាន TEUs) និងទីលានស្តុកកុងតឺន័រ (អាចស្តុកបានអតិបរមា ២៤,២០០ TEUs) ប៉ុន្តែបរិមាណកុងតឺន័រឆ្លងកាត់ កសស បានលើសពី ១លានTEUs កាលពីឆ្នាំ២០២៤ ហើយបច្ចុប្បន្នបរិមាណកុងតឺន័រស្តុកនៅទីលានមានពី ២៥,០០០ TEUs ទៅ ២៦,០០០ TEUs ដែលបានធ្វើឱ្យប្រតិបត្តិការអាជីវកម្ម នៅ កសស មានភាពអាក់រអួល ។ ដើម្បីបង្កើនប្រសិទ្ធភាព និងដោះស្រាយបញ្ហាខាងលើនេះ កសស វិនិយោគបន្ថែមក្នុងឆ្នាំ២០២៤-២០២៥ នូវទឹកប្រាក់ប្រមាណ ១០,៣លានដុល្លារអាមេរិក ដើម្បីចាក់ទីលានស្តុកកុងតឺន័រផ្ទុកទំនិញ (ទំហំ ៤,២ហិកតា) និងសម្រាប់កុងតឺន័រទទេរ (ទំហំ ៣,៥ហិកតា) បន្ថែម ដែលនឹងត្រូវបញ្ចប់នៅដំណាច់ខែកក្កដា ឆ្នាំ២០២៥ ព្រមទាំងកំពុងរៀបចំសាងសង់-កែលម្អផ្លូវ ដើម្បីសម្រួលចរាចរណ៍រថយន្តដឹកកុងតឺន័រចេញ-ចូល នៅមុខច្រកទ្វារកំពង់ផែឱ្យបានងាយស្រួល ។

ទន្ទឹមហ្នឹងនេះ ក្រុមហ៊ុននាវា និងក្រុមហ៊ុនដឹកជញ្ជូនដោយរថយន្ត ក៏សូមចូលរួមសហការដោយអនុវត្តនូវភារកិច្ចរបស់ខ្លួន ដូចខាងក្រោម ៖

- ពង្រឹងការចូលចតនាវា តាមកាលវិភាគដែលមានក្នុងកិច្ចព្រមព្រៀង និងសមស្របតាមពេលវេលា
- ក្រុមហ៊ុននាវា ត្រូវពង្រឹងការ Booking ទៅតាមសមត្ថភាពផ្ទុករបស់នាវា
- ក្រុមហ៊ុននាវា ត្រូវជម្រុញការផ្ទុកសំបកកុងតឺន័រចុះនាវា ដើម្បីឱ្យមានសមតុល្យរវាង កុងតឺន័រចូលស្តុកទីលាន និងផ្ទុកចុះនាវា
- ក្រុមហ៊ុននាវា និងក្រុមហ៊ុនដឹកញ្ជូនដោយរថយន្ត បញ្ជូនកុងតឺន័រនាំចេញ ចូលមកស្តុកក្នុង កសស ១សប្តាហ៍យ៉ាងយូរ មុននាវាចូលចត
- ក្រុមហ៊ុនដឹកជញ្ជូន ភ្នាក់ងារជើងសារ (រត់ការ) ត្រូវពន្លឿនបែបបទឯកសារជាមួយ កំពង់ផែ និងសមត្ថកិច្ច



តិរវិថី សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ
Tarak Vithei Samdech Akka Moha Sena Padei Techo HUN SEN
Sangkat N°3, Preah Sihanouk City, Preah Sihanouk Province
Office : 034 933 416; 034 933 511 Pilot : 034 933 507; Fax : 034 933 693
E-mail : pasinfo@pas.gov.kh; spsez@pas.gov.kh
Website: www.pas.gov.kh

- ភ្នាក់ងារជើងសារ រួសរាន់ប្រគល់ឯកសារជូន អ្នកបើកបររថយន្ត , ហើយរថយន្តឆាប់ចេញពី កសស
- ក្រុមហ៊ុនដឹកជញ្ជូន ពង្រឹងអ្នកបើកបរឱ្យគោរពតាមការណែនាំអំពីចរាចរណ៍ក្នុងបរិវេណ កសស និងកុំឱ្យអ្នកបើកបរចុះចោលរថយន្ត ។

ដើម្បីចូលរួមដោះស្រាយបញ្ហាខាងលើ កំពង់ផែស្វយ័តក្រុងព្រះសីហនុ (កសស) មានកិត្តិយសសូមជម្រាបជូន ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា ឧកញ៉ា លោក-លោកស្រី ប្រធានក្រុមហ៊ុននាវា ឬតំណាងក្រុមហ៊ុននាវា ប្រធាន ឬតំណាងក្រុមហ៊ុនដឹកជញ្ជូនដោយរថយន្ត មេត្តាជ្រាប និងស្នើសុំកិច្ចសហការណ៍ចូលរួមអនុវត្តន៍នូវគោលការណ៍ដូចខាងក្រោម **ចាប់ពីថ្ងៃទី០១ ខែសីហា ឆ្នាំ២០២៥** តទៅ ៖

១. ថ្លៃឈ្នួលស្តុក និងរយៈពេលស្តុក "កុងតឺន័រនាំចេញ"

| កុងតឺន័រនាំចេញ | កុងតឺន័រផ្ទុកទំនិញ | | កុងតឺន័រសំបក | |
|---|---|---|---|---|
| | ២០ហ្វីត | ៤០ហ្វីត & ៤៥ហ្វីត | ២០ហ្វីត | ៤០ហ្វីត & ៤៥ហ្វីត |
| តម្លៃស្តុកក្នុង ១ ថ្ងៃ | ៤ ដុល្លារ | ៧ ដុល្លារ | ២,២ ដុល្លារ | ៣ ដុល្លារ |
| អនុគ្រោះថ្លៃស្តុកក្នុងរយៈពេល ៤ថ្ងៃ ចាប់ពីថ្ងៃដែលកុងតឺន័រចូលស្តុកទីលានរហូតដល់ថ្ងៃនាវាចេញដំណើរ ចាប់ពីថ្ងៃទី៥ គិតថ្លៃស្តុកចំនួន ៥ថ្ងៃ និងកំណើនជាលំដាប់តាមចំនួនថ្ងៃស្តុក | | | | |

២. ថ្លៃឈ្នួលស្តុក និងរយៈពេលស្តុក "កុងតឺន័រនាំចូល" និង "កុងតឺន័រ Re-Delivery"

| កុងតឺន័រនាំចូល / កុងតឺន័រ Re-Delivery | កុងតឺន័រផ្ទុកទំនិញ | | កុងតឺន័រសំបក | |
|---|---|---|---|---|
| | ២០ហ្វីត | ៤០ហ្វីត & ៤៥ហ្វីត | ២០ហ្វីត | ៤០ហ្វីត & ៤៥ហ្វីត |
| តម្លៃស្តុកក្នុង ១ ថ្ងៃ | ៥ ដុល្លារ | ៨ ដុល្លារ | ២,២ ដុល្លារ | ៣ ដុល្លារ |
| *កុងតឺន័រនាំចូល: អនុគ្រោះថ្លៃស្តុកក្នុងរយៈពេល ៤ថ្ងៃ ចាប់ពីពេលនាវាចូលចតរហូតដល់កុងតឺន័រចេញពី កសស<br>*កុងតឺន័រ Re-Delivery: អនុគ្រោះថ្លៃស្តុកក្នុងរយៈពេល ៤ថ្ងៃ ចាប់ពីថ្ងៃដែលកុងតឺន័រចូលស្តុកទីលានរហូតដល់ចេញពី កសស<br>ចាប់ពីថ្ងៃទី៥ គិតថ្លៃស្តុកចំនួន ៥ថ្ងៃ និងកំណើនជាលំដាប់តាមចំនួនថ្ងៃស្តុក | | | | |

៣. ការជម្រុញរថយន្តដឹកកុងតឺន័រចេញពី កសស

សម្រាប់រថយន្តចូលដឹកកុងតឺន័រ ត្រូវបានអនុញ្ញាតរយៈពេល **២ម៉ោង** ក្រោយពេលកុងតឺន័របានលើកពីទីលានដាក់លើរថយន្ត រហូតដល់រថយន្តចាកចេញពីច្រកទ្វារ កសស ។

សម្រាប់រថយន្តដឹកកុងតឺន័រនាំចេញ ត្រូវបានអនុញ្ញាតរយៈពេល **១ម៉ោង** ក្រោយពេលកុងតឺន័របានដាក់ចុះនៅទីលាន រហូតដល់រថយន្តទទេចាកចេញពីច្រកទ្វារ កសស ។

ក្នុងករណីដែលរថយន្តប្រើប្រាស់រយៈពេលលើសពីរយៈពេលដែលបានកំណត់ខាងលើ, កសស សូមគិតថ្លៃសំចត ក្នុងតម្លៃ **៣ ដុល្លារ ក្នុងមួយម៉ោង** ។

*<u>បញ្ជាក់</u>: ថ្លៃឈ្នួលស្តុក និងថ្លៃសំចតខាងលើ ពុំគិតរួមបញ្ចូលអាករលើតម្លៃបន្ថែម (VAT) ១០% ទេ ។*

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម ឯកឧត្តម លោកជំទាវ ឧកញ៉ា លោក-លោកស្រី និងសាធារណជន មេត្តាយោគយល់ និងរួមគ្នាដោះស្រាយបញ្ហាប្រឈមទាំងអស់គ្នា ៕

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា**
**ទទួលបន្ទុកជាប្រធានអគ្គនាយក**

**លូ គឹមឈន់**

**ចម្លងជូន ៖**
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងសាធារណការ និងដឹកជញ្ជូន "ដើម្បីគោរពជូនជ្រាប"
- ក្រុមប្រឹក្សាភិបាល-មន្ត្រីត្រួតពិនិត្យរដ្ឋ "ដើម្បីជូនជ្រាប"
- ក្រុមហ៊ុននាវា-ក្រុមហ៊ុនដឹកជញ្ជូន "ដើម្បីចូលរួមសហការ"
- គ្រប់នាយកដ្ឋានពាក់ព័ន្ធ "ដើម្បីមុខការ"
- ឯកសារ កាលប្បវត្តិ